**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១៧១ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់ក្រសួងពាណិជ្ជកម្ម
- រៀបចំមុខងារនិងភារកិច្ចអង្គភាពនានានៃក្រសួងពាណិជ្ជកម្ម
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យពាណិជ្ជកម្ម។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពនៃក្រសួងពាណិជ្ជកម្ម ទាំងនៅថ្នាក់កណ្តាល នៅថ្នាក់មូលដ្ឋាននិងសហគ្រាសសាធារណៈ ដោយគ្របដណ្តប់លើវិស័យពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ៤ .-**

ក្រសួងពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

បេសកកម្មនេះ ត្រូវធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តឲ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម។

**មាត្រា ៥ .-**

ក្រសួងពាណិជ្ជកម្ម មានមុខងារ និងភារកិច្ច ដូចតទៅៈ

- រួមចំណែកកសាងគោលនយោបាយពាណិជ្ជកម្ម ដោយឈរលើមូលដ្ឋានច្បាប់ បទប្បញ្ញត្តិជាតិ និងអន្តរជាតិ
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- រក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ និងធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ពិសេសចំពោះមុខទំនិញជាយុទ្ធសាស្ត្រ
- ស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារ
- ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្មតាមរយៈការធ្វើពិពិធកម្មទីផ្សារ និងទំនិញនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទៅក្នុងក្របខ័ណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក
- រៀបចំ ដឹកនាំ ត្រួតពិនិត្យពាណិជ្ជកម្មក្រៅប្រទេស ផ្តល់អជ្ញាប័ណ្ណ និងវិញ្ញាបនបត្រសម្រាប់ការនាំចេញនាំចូលទំនិញតាមច្បាប់ និងបទប្បញ្ញត្តិ
- អនុវត្តនយោបាយ ដើម្បីអភិវឌ្ឍវិស័យឯកជន ធានាសេរីភាព និងសមធម៌នៃការធ្វើពាណិជ្ជកម្ម
- រៀបចំគោលនយោបាយប្រកួតប្រជែង
- តាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- អភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធ តាមរយៈអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម
- គ្រប់គ្រងការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ ចូលរួមនិងគ្រប់គ្រងពិព័រណ៍ពាណិជ្ជកម្មជាតិ និងអន្តរជាតិ
- បំពេញកាតព្វកិច្ចជាសមាជិកការិយាល័យពិព័រណ៍អន្តរជាតិ(BIE) និងកិច្ចការពិព័រណ៍ពិភពលោក
- ជំរុញឲ្យមានតុល្យភាពពង្រឹងពាណិជ្ជកម្ម
- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិសំដៅអភិវឌ្ឍផលិតផលកម្ពុជា
- សិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចជាតិ និងអន្តរជាតិ ព្រមទាំងព្យាករណ៍និន្នាការទីផ្សារសម្រាប់ផ្សព្វផ្សាយដល់ផលិតករ និងពាណិជ្ជករ
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា និងជាលេខាធិការដ្ឋាននៃគណកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា
- គ្រប់គ្រងម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈនៃទំនិញ និងសេវា និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម

- ចលនា និងផ្សព្វផ្សាយការប្រើប្រាស់ផលិតផលទំនិញនិងសេវា និងចាត់វិធានការការពារផលប្រយោជន៍ជូនអ្នកប្រើប្រាស់
- ត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផលិតផលទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នពាក់ព័ន្ធ
- បង្ក្រាបការក្លែងបន្លំផ្នែកពាណិជ្ជកម្មនៅលើទីផ្សារ រួមទាំងការតាំងពិព័រណ៍ និងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញ និងសេវា
- សម្របសម្រួលកិច្ចការត្រួតពិនិត្យ គុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវារវាងស្ថាប័នពាក់ព័ន្ធ និងសកម្មភាពការងាររបស់គូដិចជាតិ
- ផ្តល់សេវាត្រួតពិនិត្យពាណិជ្ជកម្មក្នុងនាមភាគីទី៣ ជូនការីសេដ្ឋកិច្ច
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា និងភាពអនុគ្រោះក្រោមតំបន់ពាណិជ្ជកម្មសេរី និងទ្វេភាគី ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- ធ្វើជាអាណាព្យាបាលបច្ចេកទេសសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម
- ធ្វើសហប្រតិបត្តិការនិងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្មជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជាមួយបណ្តាប្រទេស ព្រមទាំងអង្គការអន្តរជាតិនានា
- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- អភិវឌ្ឍការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- អភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងពាណិជ្ជកម្ម

**មាត្រា ៦ .-**

ក្រសួងពាណិជ្ជកម្ម មានរចនាសម្ព័ន្ធដូចខាងក្រោមៈ

ក.អង្គភាពថ្នាក់ជាតិ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម
- អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហ័ណ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)
- អគ្គាធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខ.សហគ្រាសសាធារណ:

- ក្រុមហ៊ុនគ្រឹនត្រេដ

គ.អង្គភាពថ្នាក់មូលដ្ឋានៈ

នៅថ្នាក់ក្រោមជាតិមានមន្ទីរពាណិជ្ជកម្ម សាខាកាំកុងត្រូល និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត ។

**មាត្រា ៧ .-**

អគ្គនាយកដ្ឋានដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនជាជំនួយការ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនឋានៈស្មើអគ្គនាយករង ជាជំនួយការ។

នាយកដ្ឋានដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដឹកនាំដោយប្រធានមន្ទីរមួយរូបឋានៈស្មើអនុប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមន្ទីរមួយចំនួន។

តំណាងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មានប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន អមដោយមន្ត្រីមួយចំនួនជាជំនួយការតាមការចាំបាច់។

សាខាកាំកុងត្រូលរាជធានី ខេត្ត មជ្ឈមណ្ឌលត្រួតពិនិត្យ និងផែស្ងួត ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើប្រធានការិយាល័យ និងអមដោយអនុប្រធានមួយចំនួន។

អង្គការលេខរបស់ក្រសួងពាណិជ្ជកម្ម ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៨ .–**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋាន វិទ្យាស្ថាន និងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពមូលដ្ឋាននៃក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ៩ .–**

ខុទ្ទកាល័យក្រសួងពាណិជ្ជកម្មទទួលបន្ទុកបេសកកម្មទាំងឡាយដែលបានកំណត់ក្នុងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី ៤
## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ១០ .–**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពថ្នាក់មូលដ្ឋានក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួង
- រៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ
- លើកគម្រោងរៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រសួង
- ចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១១ .–**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មាននាយកដ្ឋានចំណុះចំនួន ៣(បី) ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល
- នាយកដ្ឋានបុគ្គលិក

- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

**មាត្រា ១២ .-**

នាយកដ្ឋានរដ្ឋបាល បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងាររដ្ឋបាល។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ។

## ជំពូកទី ៥
## អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ

**មាត្រា ១៣ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- ធ្វើសហប្រតិបត្តិការ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចពាណិជ្ជកម្ម ជាមួយសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជាមួយបណ្តាប្រទេសក្នុងទ្វីបនានា
- ធ្វើសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា
- ប្រតិបត្តិរាល់នយោបាយ និងបេសកកម្មរបស់ក្រសួង ក្នុងការគ្រប់គ្រង ដឹកនាំការងារពាណិជ្ជកម្មអន្តរជាតិ
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយពាណិជ្ជកម្មក្រៅប្រទេស ឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ទទួលបន្ទុកការងារសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មក្នុងក្របខ័ណ្ឌអនុតំបន់ ក្របខ័ណ្ឌតំបន់ និងក្របខ័ណ្ឌពិភពលោក
- រៀបចំឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្មសម្រាប់ធ្វើជាមូលដ្ឋាននៃការចរចាបើកច្រកទីផ្សារ
- រៀបចំធ្វើសន្ទស្សន៍សេដ្ឋកិច្ច និងវិភាគលើស្ថានភាពពាណិជ្ជកម្មអន្តរជាតិ
- សម្របសម្រួលជំនួយទាក់ទងនឹងពាណិជ្ជកម្មជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិ
- សម្របសម្រួល និងជំរុញការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ដែលបានសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក ជាមួយអាស៊ាន និងក្នុងក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរីដទៃទៀត
- ជំរុញវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធ តាមរយៈការរៀបចំអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មទាំងមូល
- ធ្វើសហប្រតិបត្តិការជាមួយបណ្តាប្រទេស និងសហគមន៍ដៃគូអភិវឌ្ឍន៍ ដើម្បីរកឱកាសសម្រាប់បណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន
- ផ្តល់យោបល់លើសេចក្តីព្រាងច្បាប់បទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានារបស់កម្ពុជាដែលទាក់ទងនឹងកិច្ចព្រមព្រៀង សន្ធិសញ្ញាពាណិជ្ជកម្មតំបន់ និងពិភពលោកដែលកម្ពុជាជាសមាជិកហត្ថលេខី ដើម្បីធានានូវអនុលោមភាព

- ជាមជ្ឈមណ្ឌលសម្របសម្រួលសម្រាប់ទទួល និងផ្តល់ព័ត៌មានទាក់ទងនឹងវិស័យសេវាកម្ម វិស័យពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀតរបស់ព្រះរាជាណាចក្រកម្ពុជា
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១៤ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ មាននាយកដ្ឋានចំណុះចំនួន ៥(ប្រាំ) ដូចខាងក្រោម៖

- នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក
- នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- នាយកដ្ឋានអាមេរិក
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់

**មាត្រា ១៥ .-**

នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអាស៊ីប៉ាស៊ីហ្វិក។

នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក។

នាយកដ្ឋានអាមេរិក បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារពាក់ព័ន្ធជាមួយទ្វីបអាមេរិក។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារសហប្រតិបត្តិការអន្តរជាតិ។

នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ លើការងារផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ដែលពាក់ព័ន្ធជាមួយអង្គការពាណិជ្ជកម្មពិភពលោក។

## ជំពូកទី ៦
## អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស

**មាត្រា ១៦ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេសបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- អនុវត្តរាល់សកម្មភាពរបស់ក្រសួង លើគោលនយោបាយគ្រប់គ្រង ដឹកនាំពាណិជ្ជកម្មក្នុងប្រទេស
- កំណត់អំពីសន្និធិទំនិញយុទ្ធសាស្ត្រ
- តាមដានថ្លៃទំនិញ និងដំណើរការទីផ្សារ
- គ្រប់គ្រងប្រព័ន្ធព័ត៌មានទីផ្សារ(EMCS)
- ធានាសេរីភាព និងការធ្វើពាណិជ្ជកម្មប្រកបដោយសមធម៌របស់ផ្នែកឯកជន ក្នុងសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- ធ្វើជាអាណាព្យាបាលបច្ចេកទេសសភាពាណិជ្ជកម្ម និងសមាគមពាណិជ្ជកម្ម
- ជួយរៀបចំសភាពាណិជ្ជកម្ម និងជួយណែនាំលើកិច្ចការច្បាប់ និងបច្ចេកទេសទាក់ទងនឹងគោលនយោបាយពាណិជ្ជកម្ម និងសេដ្ឋកិច្ច
- ជួយចាត់ចែងកិច្ចសម្រួលពាណិជ្ជកម្ម

- គ្រប់គ្រងទីផ្សារ និងអនុវត្តគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក ដូចជាបិទស្លាកថ្លៃទំនិញ ត្រួតពិនិត្យស្តុកទំនិញយុទ្ធសាស្ត្រ និងទំនិញចាំបាច់តាមការកំណត់របស់រាជរដ្ឋាភិបាល
- តាមដានការងារដែលក្រសួងបានធ្វើប្រតិភូកម្មទៅមន្ទីរពាណិជ្ជកម្មរាជធានីខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកវិធានការទប់ស្កាត់ការលក់បង្ខូចថ្លៃ ការលក់ផ្ទួប ការលក់បោកបញ្ឆោតអតិថិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញចលនាភូមិមួយផលិតផលមួយ
- ចាត់ចែង តាក់តែងច្បាប់ពាណិជ្ជកម្ម បទប្បញ្ញត្តិពាណិជ្ជកម្ម និងគ្រប់គ្រងមជ្ឈមណ្ឌលតម្កល់ឯកសារ និងព័ត៌មានពាណិជ្ជកម្ម
- គាំទ្រដល់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម
- គ្រប់គ្រង ការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា
- រៀបចំ និងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួង
- អភិវឌ្ឍការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- រៀបចំធ្វើសន្ទស្សន៍ថ្លៃទំនិញចាំបាច់សំខាន់ៗ និងធ្វើស្ថិតិពាណិជ្ជកម្ម
- សិក្សាស្រាវជ្រាវប្រមូល និងវិភាគព័ត៌មានដើម្បីបង្កើតតារាងប្រែប្រួលថ្លៃ
- ទទួលជាមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មរបស់ក្រសួង
- កសាងផែនការយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ក្រសួង
- កសាងផែនការ និងរៀបចំកម្មវិធីសិក្សាលើគ្រប់មុខជំនាញពាក់ព័ន្ធនឹងការងារពាណិជ្ជកម្ម និងសេដ្ឋកិច្ចដើម្បីធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ទាំងរយៈពេលខ្លី មធ្យម និងរយៈពេលវែង
- ធ្វើជាយន្តការអនុវត្តការងារបណ្តុះបណ្តាល បំប៉នចំណេះដឹងដល់មន្ត្រីរាជការនៃស្ថាប័ន អង្គភាពសាធារណៈ និងបុគ្គលិក មកពីវិស័យឯកជន ឬសិស្ស និស្សិតទូទៅ ទៅតាមកម្មវិធីសិក្សា និងតាមតម្រូវការចាំបាច់
- អនុវត្តកិច្ចសហប្រតិបត្តិការ សម្របសម្រួលក្នុងការបើកវគ្គបណ្តុះបណ្តាលនានា ក្រោមគម្រោងជំនួយគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ឬពីអង្គការជាតិ និងអន្តរជាតិ
- រៀបចំការស្រាវជ្រាវ វិភាគ ឃ្លាំមើលទីផ្សារ និងលំហូរផលិតផលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ១៧ .-**

អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស មាននាយកដ្ឋានចំណុះចំនួន ៤(បួន) ដូចខាងក្រោមៈ

- នាយកដ្ឋាននីតិកម្ម
- នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន
- នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម
- វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

**មាត្រា ១៨ .-**

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារនីតិកម្ម។

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារអភិវឌ្ឍវិស័យឯកជន។

នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម។

វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស លើការងារបណ្តុះបណ្តាលពាក់ព័ន្ធជាមួយវិស័យពាណិជ្ជកម្ម និងស្រាវជ្រាវ។

## ជំពូកទី ៧
## អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម

**មាត្រា ១៩ ._**

អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្មបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្មមានភារកិច្ចដូចតទៅៈ

- អនុវត្តរាល់សកម្មភាពរបស់ក្រសួង លើគោលនយោបាយគ្រប់គ្រង និងផ្តល់សេវាពាណិជ្ជកម្ម
- ស្រាវជ្រាវ និងរៀបចំគោលនយោបាយសេវាពាណិជ្ជកម្ម
- រៀបចំ និងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការផ្តល់សេវាពាណិជ្ជកម្មឲ្យមានប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ផ្តល់សេវាពិនិត្យ និងរក្សាទុកការអនុញ្ញាតឲ្យប្រើប្រាស់នាមករក្រុមហ៊ុន សហគ្រាស
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម និងផ្តល់ព័ត៌មានពាក់ព័ន្ធ
- គ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ ការរក្សាទុកព័ត៌មាន ទិន្នន័យសហគ្រាសក្រុមហ៊ុន
- ជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា
- ទទួលបន្ទុក និងសហការរៀបចំច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងកម្មសិទ្ធិបញ្ញា
- សម្របសម្រួលការងារកម្មសិទ្ធិបញ្ញា គ្រប់គ្រងដោយផ្ទាល់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម៉ាកការសម្គាល់ភូមិសាស្ត្រទំនិញ ម៉ាកសមូហភាព ម៉ាកបញ្ជាក់អំពីចរិកលក្ខណៈនៃទំនិញ និងសេវា និងការការពារព័ត៌មានសម្ងាត់ពាណិជ្ជកម្ម
- ជាអង្គភាពសម្របសម្រួលកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីលើវិស័យកម្មសិទ្ធិបញ្ញាជាមួយបណ្តាប្រទេស និងអង្គការអន្តរជាតិនានា
- សហការជាមួយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នតុលាការដើម្បីបញ្ឈប់ការរំលោភបំពានកម្មសិទ្ធិបញ្ញា ដោះស្រាយវិវាទនានាទាក់ទងនឹងកម្មសិទ្ធិបញ្ញាដែលជាសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្ម
- ជំរុញការធ្វើពាណិជ្ជកម្មកម្មសិទ្ធិបញ្ញា និងការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា
- គ្រប់គ្រង និងអនុវត្តបទប្បញ្ញត្តិ នៃប្រព័ន្ធអនុគ្រោះទូទៅ និងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មនានា ព្រមទាំងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ
- រៀបចំ និងអនុវត្តលិខិតបទដ្ឋានបច្ចេកទេស និងច្បាប់ទាក់ទងនឹងវិធានប្រភពដើមទំនិញ ក្រោមក្របខ័ណ្ឌប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងតំបន់ពាណិជ្ជកម្មសេរីនានា
- រៀបចំ និងពិនិត្យឯកសារចេញវិញ្ញាបនបត្រប្រភពដើមទំនិញ សម្រាប់ការនាំចេញទំនិញ ទៅកាន់ប្រទេសអាស៊ាន និងប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា
- គ្រប់គ្រងការចេញវិញ្ញាបនបត្របញ្ជាក់អត្តសញ្ញាណផលិតផល Halal

- គ្រប់គ្រងការចេញវិញ្ញាបនបត្រត្បូងពេជ្រមិនទាន់កែច្នៃក្រោមការអនុវត្តគម្រោងគីមប័រលីប្រូសេស (Kimberly Process)
- ទទួលបន្ទុកជាអង្គភាពសម្របសម្រួលក្នុងនាមកម្ពុជាជាសមាជិកនៃអង្គការគីមប័រលី
- គ្រប់គ្រងការនាំចូលផ្ទាំងក្រណាត់ចាក់
- ចេញអាជ្ញាប័ណ្ណនាំចេញ នាំចូលទំនិញផ្អែកតាមច្បាប់ បទប្បញ្ញត្តិ និងតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ២០ ._**

អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣(បី) និងមានតំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស ជាអង្គភាពមូលដ្ឋានដូចខាងក្រោម៖

- នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- នាយកដ្ឋាននាំចេញ នាំចូល
- តំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស

**មាត្រា ២១ ._**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារចុះបញ្ជីពាណិជ្ជកម្ម។

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារកម្មសិទ្ធិបញ្ញា។

នាយកដ្ឋាននាំចេញ នាំចូល បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងារនាំចេញ នាំចូល។

តំណាងពាណិជ្ជកម្មតំបន់សេដ្ឋកិច្ចពិសេស បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម លើការងាររៀបចំ ពិនិត្យឯកសារ និងចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស។

## ជំពូកទី ៨
## អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

**មាត្រា ២២ ._**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- ជួយរកទីផ្សារជូនកសិករ និងពាណិជ្ជករ
- ស្រាវជ្រាវ និងអភិវឌ្ឍទីផ្សារ
- រៀបចំ និងចូលរួមពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសព្រមទាំងធ្វើការណែនាំ និងលើកទឹកចិត្តដល់ការចូលរួមរបស់ផលិតករ និងអាជីវករជាតិនៅក្នុងកម្មវិធីពិព័រណ៍ក្រៅប្រទេស
- គ្រប់គ្រងមជ្ឈមណ្ឌលពិព័រណ៍ពាណិជ្ជកម្មជាតិខេត្ត ក្រុង និងតំបន់
- សម្របសម្រួលលើកទឹកចិត្ត គ្រប់គ្រង និងចេញលិខិតអនុញ្ញាតដល់ការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ដែលរៀបចំដោយក្រុមហ៊ុនក្នុងស្រុក ក្រុមហ៊ុនបរទេស និងស្ថាប័ននានា

- ទទួលបន្ទុកជាចំណុចប្រសព្វ សម្រាប់ការងារការិយាល័យពិព័រណ៍អន្តរជាតិ (BIE) និងការងារជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការអន្តរក្រសួង ដើម្បីរៀបចំចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ
- រៀបចំយុទ្ធសាស្ត្រស្វែងរកទីផ្សារ ស្រាវជ្រាវវិភាគ និងកសាងគោលនយោបាយទីផ្សារនិងជំរុញការនាំចេញ
- រៀបចំ និងទទួលបេសកកម្មពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ក្នុងបំណងបង្កើតនូវវេទិកាដៃគូពាណិជ្ជកម្ម ឬជំនួបពាណិជ្ជកម្ម សម្រាប់ពាណិជ្ជកម្មក្នុង និងក្រៅប្រទេសដោយសហការជាមួយអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស
- សិក្សាស្រាវជ្រាវ និងវិភាគសកម្មភាពពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយជូនរាជរដ្ឋាភិបាល
- សហប្រតិបត្តិការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក រួមមានមជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-ចិន មជ្ឈមណ្ឌលពាណិជ្ជកម្មអាស៊ាន-កូរ៉េ។ល។
- រៀបចំ និងចាត់ចែងសិក្ខាសាលា សន្និសីទ វេទិកាពាណិជ្ជកម្ម និងកិច្ចប្រជុំស្តីពីការជំរុញពាណិជ្ជកម្ម សម្រាប់បង្កើតឲ្យមានដៃគូពាណិជ្ជកម្ម
- ចូលរួមកសាង និងអនុវត្តគោលនយោបាយផលិតផលជាតិ ក្នុងគោលដៅបម្រើទីផ្សារក្នុងស្រុក និងនាំចេញ
- ចូលរួមអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ជាមួយស្ថាប័នពាក់ព័ន្ធ
- សិក្សាស្រាវជ្រាវលើផលិតផលថ្មីៗ និងការអភិវឌ្ឍន៍ផលិតផលដែលជាសក្តានុពលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងទីផ្សារនាំចេញ
- ធ្វើជាអ្នកពិគ្រោះយោបល់ និងប្រឹក្សាលើកិច្ចការទីផ្សារ និងពាណិជ្ជកម្ម
- ផ្សព្វផ្សាយព័ត៌មានដែលទាក់ទងជាមួយការងារជំរុញពាណិជ្ជកម្ម និងទីផ្សារក្រៅប្រទេស
- ផ្សព្វផ្សាយ និងធ្វើទំនាក់ទំនងជាមួយទីផ្សារអន្តរជាតិ តាមរយៈការដាក់តំណាងពាណិជ្ជកម្ម
- គ្រប់គ្រងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្មក្នុង និងក្រៅប្រទេស
- រៀបចំ និងគ្រប់គ្រងគេហទំព័រសម្រាប់ជំរុញពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

**មាត្រា ២៣ .-**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម មាននាយកដ្ឋានចំណុះចំនួន ៣(បី) ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការពិព័រណ៍
- នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ
- នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម

និងមានតំណាងពាណិជ្ជកម្ម (ទីប្រឹក្សា និងអនុព័ន្ធពាណិជ្ជកម្ម) ប្រចាំការនៅក្រៅប្រទេស។

**មាត្រា ២៤ .-**

នាយកដ្ឋានកិច្ចការពិព័រណ៍បំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មលើការងារកិច្ចការពិព័រណ៍។

នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារបំពេញមុខងារជាសេនាធិការឲ្យអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្មលើការងារអភិវឌ្ឍន៍ទីផ្សារ។

នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឲ្យ អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម លើការងារជំរុញការអនុវត្តន៍ កែលម្អ និងអភិវឌ្ឍគោលនយោបាយពាណិជ្ជកម្ម។

តំណាងពាណិជ្ជកម្មក្រៅប្រទេស បំពេញមុខងារធ្វើទំនាក់ទំនង ផ្សព្វផ្សាយ និងផ្តល់ព័ត៌មាន ពាក់ព័ន្ធការងារសេដ្ឋកិច្ច និងពាណិជ្ជកម្មនៅប្រទេសដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗជាមួយព្រះរាជាណាចក្រកម្ពុជា អមស្ថានឯកអគ្គរាជទូតកម្ពុជា។

## ជំពូកទី ៩

## អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល)

**មាត្រា ២៥ .-**

អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) បំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋាន កម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ(កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញ នីហរណ៍ អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ១០

## អគ្គាធិការដ្ឋាន

**មាត្រា ២៦ .-**

អគ្គាធិការដ្ឋានបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម មានភារកិច្ចដូចតទៅៈ

- ធ្វើអធិការកិច្ចលើដំណើរការរដ្ឋបាលរបស់ក្រសួង អង្គភាពក្រោមឱវាទ សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យពាណិជ្ជកម្ម
- ធ្វើការតាមដាន និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិនានា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់មន្ត្រីដែលកំពុងគ្រប់គ្រងលើវិស័យពាណិជ្ជកម្មឲ្យទទួលខុសត្រូវតាមវិធានការ វិន័យរដ្ឋបាល និងតុលាការ
- ចុះត្រួតពិនិត្យពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិលដែលទាក់ទងការគ្រប់គ្រងវិស័យពាណិជ្ជកម្ម
- ធ្វើអធិការកិច្ចលើវិវាទពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ធ្វើរបាយការណ៍សកម្មភាពការងារជូនក្រសួង
- បំពេញភារកិច្ចផ្សេងៗ ទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួង។

## ជំពូកទី ១១

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ២៧ .-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងបំពេញមុខងារជាសេនាធិការឲ្យក្រសួងពាណិជ្ជកម្ម ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ៤០អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៅតាមស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ។

## ជំពូកទី ១២
## អង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងពាណិជ្ជកម្ម

**មាត្រា ២៨ .-**

ក្រសួងពាណិជ្ជកម្មមានអង្គភាពថ្នាក់ក្រោមជាតិដែលជាមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តដើម្បីបំពេញមុខងារពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី ១៣
## សហគ្រាសសាធារណៈ

**មាត្រា ២៩ .-**

អង្គភាពសហគ្រាសសាធារណៈជានីតិបុគ្គល ដែលទទួលបន្ទុកធ្វើការងារតាមជំនាញឯកទេសរបស់ខ្លួនស្របតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ និងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្រ្គីនត្រេដ។

## ជំពូកទី ១៤
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ៣០ .-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌ នៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល។

## ជំពូកទី ១៥
## អន្តរប្បញ្ញត្តិ

**មាត្រា ៣១ .-**

ប្រកាសស្តីពីការបង្កើត ឬ ការរៀបចំនិងការប្រព្រឹត្តទៅការិយាល័យនានាចំណុះឲ្យអគ្គនាយកដ្ឋាន ឬអគ្គាធិការដ្ឋាន ឬនាយកដ្ឋាន ឬមជ្ឈមណ្ឌល ឬអង្គភាពនានានៃក្រសួងពាណិជ្ជកម្ម ត្រូវបន្តមានសុពលភាពអនុវត្តរហូតដល់មានប្រកាសថ្មីរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

ការរៀបចំ និងការប្រព្រឹត្តទៅថ្នាក់ក្រោមនាយកដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

## ជំពូកទី ១៦
## អវសានប្បញ្ញត្តិ

**មាត្រា ៣២ .-**

ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងសហការណ៍ជាមួយប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តការងារតាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងប្រធានស្ថាប័ននោះ។

**មាត្រា ៣៣ .-**

អនុក្រឹត្យនេះត្រូវជំនួសអនុក្រឹត្យដូចខាងក្រោមៈ

- អនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម។

**មាត្រា ៣៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

Chanthol Sun

**ស៊ុន ចាន់ថុល**

**<u>កន្លែងទទួល:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៣៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធក្រសួងពាណិជ្ជកម្ម

